**សុន្ទរកថារបស់ លោក ម៉ាត់ស៊ូម៉ូតុ អ៊ីហារូមី**

លេខាទីពីរ ផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍន៍ផ្លូវការ

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីសម្ពោធអគារសិក្សាថ្មីមួយខ្នងនៅអនុវិទ្យាល័យឃីឡឹក

ក្នុងស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

**ថ្ងៃទី ០២ ខែធ្នូ ២០១៦**

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- សូមគោរព **លោកជំទាវ ម៉ុក ណាឌី** អភិបាលរងនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ
- សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានមកចូលរួមក្នុងពិធីសម្ពោធអគារសិក្សាមួយខ្នង នៅអនុវិទ្យាល័យឃីឡឹក ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ ម៉ុក ណាឌី** អភិបាលរងនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ។ ជាបឋម ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ ដែលបានបញ្ចប់គម្រោងនេះប្រកបដោយជោគជ័យ ព្រមទាំងរៀបចំពិធីសម្ពោធនេះឡើង។

ខ្ញុំសូមសម្តែងនូវការកោតសរសើរ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការកែលម្អវិស័យអប់រំ នៅប៉ុន្មានឆ្នាំនេះ។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃការអប់រំថា ជាគន្លឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនោះ រដ្ឋាភិបាលជប៉ុន បាននឹងកំពុងបន្តគាំទ្រជំនួយឧបត្ថម្ភរបស់ខ្លួនដល់កម្ពុជា តាមរយៈគ្រោងការណ៍ជាច្រើនបែបដែលក្នុងនោះក៏មាន គ្រោងការណ៍ជំនួយឥតសំណងជប៉ុនសម្រាប់គម្រោងទ្រង់ទ្រាយតូច ហៅកាត់ថា "គម្រោងគូសាណូណេ"។ គម្រោងនេះ គឺជាគម្រោងលើកទី៥ហើយ ដែលត្រូវបានផ្តល់ជូនដោយគម្រោងគូសាណូណេ នៅក្នុងខេត្តបន្ទាយមានជ័យនេះ។

ខ្ញុំបានទទួលដំណឹងថា សិស្សានុសិស្សប្រមាណជា ២៨២នាក់នៅអនុវិទ្យាល័យឃីឡឹកនេះ ត្រូវសិក្សានៅក្នុងបរិស្ថានសិក្សាដែលមិនមានផាសុខភាព និងសុវត្ថិភាព។ តែឥឡូវនេះ បានជំនួសមកវិញដោយអគារសិក្សាថ្មីមួយខ្នងមាន៥បន្ទប់ដោយបំពាក់បរិក្ខារសិក្សា ព្រមទាំងបង្គន់អនាម័យចំនួន៤បន្ទប់ ដែលទើបតែត្រូវបានសាងសង់រួចផងដែរ។

ខ្ញុំពិតជាមានសេចក្តីរីករាយក្រៃលែងដែលបានឃើញ សិស្សានុសិស្សនៃអនុវិទ្យាល័យឃីឡឹកនេះ អាចសិក្សានៅក្នុងអគារសិក្សាដែលប្រកបដោយសុវត្ថិភាព និងផាសុខភាព។ ខ្ញុំសង្ឃឹមថា អគារសិក្សាថ្មីនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវល្អ ដើម្បីទុកជានិមិត្តរូបដ៏យូរអង្វែងមួយនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើអោយគម្រោងនេះដំណើរការទៅបានដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**